**គារិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស**

**សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌សំរាប់មនុស្សចាស់ ០៨,១២,៩៥**

**CESR ការជូនយោបល់ទូទៅលេខ ៦ (ការជូនយោបល់ទូទៅ)**

**<u>សេចក្តីសង្ខេបទូទៅ ៦</u>**

**សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌សំរាប់មនុស្សចាស់**

**សម័យប្រជុំលើកទី ១៣ ឆ្នាំ ១៩៩៥**

**I. សេចក្តីផ្តើម**

1. ប្រជាជនសកលលោកមានអាយុស្ថិតក្នុងអត្រាមួយនៅនឹង ហើយអត្រានោះគួរឱ្យចាប់អារម្មណ៍ខ្លាំងបំផុត ។ ចំនួនមនុស្សសរុបដែលមានអាយុ 60 ឆ្នាំ និងលើសពីនេះមានចំនួនច្រើនជាង 200 លាននាក់នៅក្នុងឆ្នាំ 1950 ហើយ 400 លាននាក់នៅក្នុងឆ្នាំ 1982 និងឡើងរហូតទៅដល់ 600 លាននាក់នៅឆ្នាំ 2025 ឬមួយជាង 70% នៃពួកគាត់រស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ សព្វថ្ងៃនេះចំនួនមនុស្សអាយុ 80 ឆ្នាំបានកើនឡើង និងកើនឡើងក្នុងសង្វាក់ឆាប់រហ័សជាទីបំផុតគឺនៅឆ្នាំ 1950 មានចំនួនលើសពី 13 លាននាក់ហើយឥឡូវនេះមានចំនួន 50 លាននាក់ហើយនិងឈានដល់ 137 លាននាក់នៅឆ្នាំ 2025 ។ ក្រុមប្រជាជនមានអត្រាកំណើនលឿនខ្ពស់បំផុតនៅលើពិភពលោក ហើយតាមការទស្សន៍ទាយផ្សេងៗចំនួនប្រជាជនទាំងនោះ និងកើនឡើងជាង 10 ដង រវាងពីឆ្នាំ 1950 និង ឆ្នាំ 2025 ដែលក្នុងរយៈពេលដូចគ្នានេះដែរចំនួនមនុស្សចាស់អាយុ 60 ឆ្នាំ និងលើសពីនេះនឹងកើន 6 ដង ហើយចំនួនសរុបនៃប្រជាជនរស់នៅលើផែនដីកើនឡើងជាង 3 ដង ។ <u>១/</u>

2. តួលេខទាំងនេះបញ្ជាក់ឱ្យឃើញថា ជាការប្រែប្រួលស្ងាត់ៗ ដោយបច្ច័យទាំងអស់ពុំអាចគិតបំរុងទុកជាមុនបានហើយកំពុងតែជះឥទ្ធិពលដល់រចនាសម្ពន្ធ័ សង្គមកិច្ច និង សេដ្ឋកិច្ចនៃសង្គមទាំងក៏រិតពិភពលោក និង ក៏រិតជាតិ ហើយនឹងជះឥទ្ធិពលដល់ប្រព័ន្ធទាំងពីរនោះច្រើនថែមទៀតនាថ្ងៃ អនាគត ។

3. ភាគច្រើននៃរដ្ឋជាភាគីទាំងអស់របស់សន្ធិសញ្ញា ជាពិសេសប្រទេសឧស្សាហកម្មបានលើកឡើងថា ការអនុវត្តយកលំនាំតាមនយោបាយសេដ្ឋកិច្ច និង សង្គមកិច្ចស្តីពីភាពចាស់ជរានៃប្រជាជន ជាពិសេសស្តីពីសន្តិសុខសង្គម ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ការបាត់បង់សន្តិសុខសង្គម ឬការថែមថយខាងផ្លូវកាយនិងស្មារតីធ្វើឱ្យមានអ្នករត់ចាកចេញពីស្រុកកាន់តែធ្ងន់ធ្ងរ ធ្វើឱ្យចុះខ្សោយតួនាទីប្រពៃណីរបស់គ្រួសារ និងការគាំទ្រចម្បងពីមនុស្សចាស់ ។

## II. នយោបាយដែលទទួលយកជាលក្ខណៈអន្តរជាតិនាត់នងមនុស្សចាស់

4. នៅឆ្នាំ 1982 សន្និបាតពិភពលោកស្តីពីមនុស្សចាស់បានអនុម័តផែនការណ៍ការងារអន្តរជាតិនៅទីក្រុង Vienne ស្តីពីជរាភាព ។ ឯកសារសំខាន់នេះបានព្រមព្រៀងដោយមហាសន្និបាត ហើយផែនការណ៍នោះជាមគ្គុទ្ទេសមួយដ៏មានប្រយោជន៍ ពីព្រោះវាពិពណ៌នានូវវិធានការណ៍ដែលត្រូវអនុវត្តដោយរដ្ឋជាសមាជិកទាំងអស់ ដើម្បីធានាសិទ្ធិមនុស្សចាស់ក្នុងក្របខ័ណ្ឌសិទ្ធិដែលបានប្រកាសនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ។ ក្នុងនោះមានអនុសាសន៍ចំនួន 62 ដែលមួយចំនួនទាក់ទងនឹង កតិកាសញ្ញាផ្ទាល់ ។ ២/

5. នៅឆ្នាំ 1991 មហាសិន្និបាតបានព្រមព្រៀងលើគោលការណ៍នានារបស់សហប្រជាជាតិសំរាប់មនុស្សចាស់ ដោយសំអាងទៅលើវិធានការណ៍ដែលបានគិតគូរពិចារណាក៏បង្កើតឧបករណ៍សំខាន់មួយនៅក្នុងបរិបទបច្ចុប្បន្ន ។ ៣/ គោលការណ៍នោះចែកចេញជា 5 ផ្នែកដែលមានទំនាក់ទំនងស្និតរមួតទៅនឹងសិទ្ធិដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញា ។ ឯករាជ្យភាពលាតសន្ធឹងជាអាទិ៍លទ្ធភាពអាចឈានទៅ ដល់បាននូវស្បៀងអាហារ ទឹក លំនៅដ្ឋាន សម្លៀកបំពាក់ និងការថែទាំសុខភាព ។ តាមរយៈសិទ្ធិជាសារៈវន្តទាំងនេះត្រូវបំពេញនូវលទ្ធភាពដោយធ្វើការងារមានប្រាក់ឈ្នួល និងឱ្យមានការអប់រំនិងបណ្តុះបណ្តាល ។ "ការចូលរួម" មានន័យថា ជនចាស់ជរាត្រូវតែចូលរួមយ៉ាងសកម្មក្នុងការឱ្យនិយមន័យ និងការអនុវត្តគោលនយោបាយដែលទាក់ទងសុខមាលភាពចែករំលែកចំពោះដឹង និងការឈ្លាសវៃដល់យុវវ័យជំនាន់ក្រោយ និងអាចបង្កើតជាចលនា ឬសមាគមផ្សេងៈ ។ នៅផ្នែកនេះផ្តើមថា " ការថែទាំ" គេបានត្រៀមថា ជនចាស់ជរាត្រូវតែបានទទួលនូវការពារគ្រួសារ និងថែទាំសុខ

ភាព និងទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារៈវន្ត័ នៅពេលដែលពួកគាត់ រស់នៅក្នុងលំនៅដ្ឋានជា គ្រួសារ ឬក្នុងមជ្ឈមណ្ឌលគាំពារ និងព្យាបាល ។ យោងទៅលើ "កាបំពេញកិច្ចការផ្ទាល់ខ្លួន" គោលការណ៍ចែងថា មនុស្សចាស់ជរាត្រូវតែមានឱកាសទទួលបាននូវធនធានពីសង្គមបេស់ពួកគេលើការងារអប់រំ វប្បធម៌ ផ្លូវចិត្ត និងស្តីពីភាពទំនេរក្រៅពីការងារ ។ ទីបញ្ចប់នៅក្នុងផ្នែកនេះដាក់ចំណងជើង "ភាពថ្លៃថ្នូរ" បាននិយាយថា មនុស្សចាស់ត្រូវតែទទួលបាននូវការរស់នៅក្នុងសេចក្តីថ្លៃថ្នូរ និងសន្តិសុខ ហើយគេចផុតពីការគេញប្រវញ្ច រំលោភលើរាងកាយ និងសតិអារម្មណ៍របស់គាត់ត្រូវផ្តល់ នូវភាពយុត្តិធម៌មិនដល់គាតិ មិនប្រកាន់រើសអើងពីអាយុ ភេទ ពូជសាសន៍ ឬកំណើតជេតពន្ធរបស់គាត់ កាយវិកលរបស់គាត់ ស្ថានភាពហិរញ្ញវត្ថុ ឬលក្ខណៈផ្សេងៗទៀត ហើយត្រូវវាយតម្លៃដាច់ដោយ ឡែកស្តីពីការចូលរួមវិភាគទានផ្នែកសេដ្ឋ កិច្ចរបស់ពួកគាត់ ។

6. នៅឆ្នាំ 1992 មហាសន្និបាតបានអនុម័តទិសដៅពិភពលោក 8 ចំណុចទាក់ទងជរាភាពសំរាប់ឆ្នាំ 2001 និងសេចក្តីណែនាំដើម្បីកំណត់គោលដៅរបស់ជាតិ ។ ទិសដៅពិភពលោកទាំងនោះបានរួមចំណែកក្នុងការពង្រឹងកតព្វកិច្ចរដ្ឋជាភាគីទាំងអស់ចូលក្នុងកតិកាសញ្ញាតាមរយៈចំណុចសំខាន់ផ្សេងៗដែលបានចែង ។៤/

7. នៅឆ្នាំ 1992 នេះដែរក្នុងឱកាសអបអរសាទរទិវាខួបលើកទី 10 នៃការអនុម័តផែនការការងារអន្តរជាតិនៅទីក្រុង Vienne ដោយសន្និបាតពិភពលោកស្តីពីជរាភាព " ហើយបានសន្យាថា និងគាំទ្រការផ្តួចផ្តើមគំនិតកិរិតថ្នាក់ជាតិទាក់ទងជរាភាព ដើម្បីប្រយោជន៍ឱ្យស្ត្រីចាស់ជរាទទួលបាននូវការគាំទ្រចំពោះអ្វីដែលគាត់ត្រូវការ ហើយយើងត្រូវគិតពីវិភាគទានធំធេងរបស់គាត់ដែលគាត់បានផ្តល់ជូនសង្គម ហើយបុរសចាស់ជរា ក៏យើងត្រូវលើកទឹកចិត្តអភិវឌ្ឍន៍សម្បទាសង្គម វប្បធម៌ និង ផ្តល់សមត្ថភាពផ្នែកសតិអារម្មណ៍ជូនគាត់ ក្រុមគ្រួសាររបស់គាត់នឹងត្រូវបានគេ ផ្តល់ការគាំទ្រផ្នែកការថែទាំសុខភាពដោយមិនបានទទួលការអភិវឌ្ឍន៍ទាល់តែសោះហើយគ្រួសារត្រូវទទួលការគាំទ្រ ដើម្បីផ្គត់ផ្គង់ផ្នែកថែទាំ ហើយសមាជិកគ្រួសារត្រូវបានជំរុញធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រឆ្នាំ 2001 ដើម្បីឈានឱ្យដល់គោលដៅពិភពលោកទាក់ទងជរាភាព។ ម្យ៉ាងទៀតឆ្នាំ

1999 ជាឆ្នាំដែលប្រកាសថា " ឆ្នាំអន្តរជាតិសំរាប់មនុស្សចាស់ក្នុងការទទួលស្គាល់ទៅលើការជឿនលឿន ខាងប្រជាសាស្ត្រនៃមនុស្សជាតិ ។៥/

8. ស្ថាប័នជំនាញនៃអង្គការសហប្រជាជាតិ ជាពិសេសអង្គការការងារអន្តរជាតិ (ILO) បានយកចិត្តទុកដាក់ចំពោះបញ្ហាជរាភាពក្នុងវិស័យសកម្មភាពជាសមត្ថកិច្ចរបស់ខ្លួន ។

## III. សិទ្ធិមនុស្សចាស់ទាក់ទងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

9. ពាក្យបច្ចេកទេសប្រើសំរាប់សំគាល់មនុស្សចាស់ប្រែប្រួលយ៉ាងច្រើនដូចមាននៅក្នុងឯកសារអន្តរជាតិជាដើម ។ គេអាចរាប់បញ្ចូលៈ មនុស្សចាស់ មជ្ឈិមវ័យ បជ្ឈិមវ័យ ( មនុស្ស៣ជំនា ន់) ជរាភាព ( មនុស្ស ៤ ជំនាន់) ដើម្បីសំគាល់មនស្សចាស់ថាមានអាយុពី 80 ឡើងទៅ ។ គណៈ កម្មាធិការជ្រើសរើសពាក្យ " នីតិជន " ("មនុស្សចាស Older person") ប្រើក្នុងសេចក្តីសំរេច នានា 47/5 និង 48/98 នៃមហាសន្និបាតហើយតាមរយៈមហាសន្និបាតគេច្បប្រើ ពាក្យមនុស្ស ចាស់អាយុ 60ឆ្នាំ និងលើសពីនេះ ស្រមតាមគំរូសេវាស្តីពីស្ថិតិរបស់សហភាពអឺរ៉ុប ហៅមនុស្សចាស់ គឺចាប់ពីអាយុ 65 ឬលើសពីនេះ ។ អាយុ 65 ឆ្នាំ គឺជាអាយុដែលចូលនិវត្តន៍ជាពាក្យដែលគេចងចាំ ហើយជួនកាលក៏មានការមិនទទួលយកដែរ ។

10. កតិកាសញ្ញាអន្តរជាតិទាក់ទងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធមិមិនមានចែងច្បាស់លាស់ចំពោះសិទ្ធិមនុស្សចាស់ឡើយ ហើយនៅមាត្រា ៩ ទាក់ទង" សិទ្ធិផ្នែកសន្តិសុខសង្គមសំរាប់មនុស្សគ្រប់រូបរួមមានការធានាសង្គម " បានសន្សាច្បាស់លាស់ទទួលស្គាល់សិទ្ធិគោរពជរាភាព ។ ដោយយល់ឃើញថា បទបញ្ញត្តិនៃសន្ធិសញ្ញាកំពុងអនុវត្តពេញ ទំហឹងចំពោះសមាជិកទាំងអស់នៃសង្គម ដូច្នេះជាការពិតណាស់ដែលមនុស្សចាស់ត្រូវតែទទួលបាននូវសិទ្ធិទាំងអស់ដែកមានចែងនៅក្នុងសន្ធិសញ្ញា ។ គោលការណ៍នេះក៏ត្រូវបានឧទ្ទិសទាំងស្រុង នៅក្នុងផែនការណ៍ការងារ អន្តរជាតិទីក្រុង Vienne ស្តីពីមនុស្សចាស់ ។ ម្យ៉ាងទៀតដោយយល់ឃើញថា ការគោរពសិទ្ធិមនុស្សចាស់តម្រូវឱ្យមានវិធានការណ៍ពិសេសរដ្ឋភាគីទាំងអស់ដើម្បីជាគុណប្រយោជន៍ដល់សន្ធិសញ្ញាត្រូវតែទទួលយកនូវកតព្វកិច្ចអនុវត្តគ្រប់វិធានការណ៍ទាំងអស់ពីធនធានដែលមិនទាន់ចាត់ចែង ។

11. បញ្ហាសំខាន់មួយទៀត គឺថាតើការរើសអើងផ្អែកទៅលើអាយុនោះត្រូវបានហាមឃាត់ដោយកតិកាសញ្ញាដែរឬទេ ។ កតិកាសញ្ញា ឬ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សមិនបានពន្យល់ច្បាស់លាស់ពីអាយុ ដូចដែលហេតុផលហាមឃាត់ទាំងឡាយនោះទេ ។ ជាជាងការដែល ពិនិត្យឃើញថាមានការមិនដាក់បញ្ចូលដោយចេនា ហើយការខកខាននេះប្រហែលជាមានការពន្យល់ដោយផ្អែកលើមូលហេតុថា នៅដែលគេអនុមតិឧបករណ៍ទាំងនេះ បញ្ហាទាក់ទងទៅនឹងអាយុប្រជាសាសន៍មិនមានលក្ខណៈជាក់ស្តែង ឬ ជាសម្ពាធដូចជាបច្ចុប្បន្ននេះទេ ។

12. ក៏ប៉ុន្តែបញ្ហានៅបើកទូលាយបើសិនជាគេគិតថា ការហាមឃាត់មិនឱ្យមានការរើសអើងសំអាងលើហេតុផលនៃស្ថានភាពផ្សេងទៀតនោះ "អាចអនុវត្តលើបញ្ហាអាយុ។ គណៈកម្មាធិការបានសង្កេតឃើញថា បើសិនជាមិនអាចសន្និដ្ឋានថា ការរើសអើងពីអាយុត្រូវបានហាមឃាត់ដោយសន្និសញ្ញានោះតែការរើសអើងនោះក៏មានកំណត់ក្នុងវិស័យនានាជាច្រើនដែរ ។ ហើយយើងគួរកត់ចំណាំថាឧបករណ៍អន្តរជាតិខាងនយោបាយទូទៅមួយ ភាគធំបញ្ជាក់ថាការរើសអើងពិតជាមិនអាចទទួលបានទេសំរាប់មនុស្សចាស់ជរា ហើយគោលការណ៍ នេះត្រូវបានបញ្ជាក់នៅក្នុងច្បាប់នៃរដ្ឋភាគីច្រើនរួចហើយ ។ នៅក្នុងវិស័យតិចតួចដែលការរើសអើងនៅមានបន្តនោះ ឧទាហរណ៍ទាក់ទងអាយុកំណត់ឱ្យចូលនិវត្តន៍ ឬ ការចូលរៀនឧត្តមសិក្សា ការអស់ទាំងនេះគេបានគិតថាត្រូវតែលុបចោលកុំឱ្យមានការហាមឃាត់តទៅទៀត ។ គណៈកម្មាធិការវាយតម្លៃថារដ្ឋទាំងអស់ត្រូវតែប្រឹងប្រែងពង្រីកនិន្នការប្រឆាំង នឹងការហាមឃាត់ដោយប្រើនូវគ្រប់ បច្ចេកបាយដែលមាន ។

13. អាស្រ័យហេតុនេះ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ចសង្គម និង វប្បធម៌ពិចារណាឃើញថា រដ្ឋភាគីនៃសន្និសញ្ញាទាំង អស់មានកតព្វកិច្ចយកចិត្តទុកដាក់ជាពិសេសលើការផ្សព្វផ្សាយ និង ការការពារសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌ ចំពោះមនុស្សចាស់ ។ តួនាទីរបស់គណៈកម្មាធិការផ្ទាល់ចំពោះរឿងនេះគឺភាពខុសគ្នានៃសិទ្ធិរបស់ក្រុមផ្សេង ដូចជាសិទ្ធិស្ត្រី និង កុមារ សិទ្ធិមនុស្សចាស់មិនបានចែងនៅក្នុងឧបករណ៍អន្តរជាតិទាំងមូលទេ ហើយក៏គ្មានជាដាច់ខាតនូវយន្តការត្រួតពិនិត្យជាក់ច្បាស់ណាមួយក្នុងការអនុវត្តគោលការណ៍ទាំងស្រុងរបស់សហប្រជាជាតិ ក្នុង វិស័យនេះដែរ ។

14. នៅទីបញ្ចប់នៃសន្និបាតលើកទី 13 របស់ខ្លួន គណៈកម្មាធិការ ដោយមានក្រុមការងារ ជំនាញការរដ្ឋាភិបាលបានពិនិត្យរបាយការណ៍បឋមចំនួន 144 របាយការណ៍ទៀងទាត់វគ្គទី 2 ចំនួន 70 និងរបាយការណ៍ទាក់ទងរបាយការណ៍បឋមជាមួយរបាយការណ៍ទៀតទាត់ចំនួន 20 ស្តីពីការអនុវត្តចាប់ពីប្រការ 1 ដល់ 15 ។ ការពិនិត្យលើ របាយការណ៍បានធ្វើឱ្យគេរកឃើញនូវបញ្ហាធំៗមួយចំនួនដែលសន្ធិសញ្ញាអាចដាក់បទបញ្ជាឱ្យរដ្ឋភាគីមួយចំនួនធំ តំណាងឱ្យគ្រប់តំបន់នៃពិភពលោកជួយសំរួលប្រព័ន្ធនយោបាយ សេដ្ឋកិច្ចសង្គម និង វប្បធម៌ផ្សេងគ្នា ។ របាយការណ៍ដែលបានពិនិត្យមកដល់ឥឡូវនេះ មិនទាន់មានសេចក្តីពិស្តារណាមួយនិយាយពីការប្រតិបត្តិតាមមាត្រាទាក់ទងនិងសិទ្ធិខាងសន្តិសុខសង្គមនៅឡើយទេ ។

15. នៅឆ្នាំ 1993 គណៈកម្មាធិការបានប្រើពេលចំនួនមួយថ្ងៃដើម្បីជជែកជាទូទៅពីបញ្ហានេះដើម្បីតម្រង់ទិសពី សកម្មភាពទៅអនាគតឱ្យបានច្បាស់លាស់ ។ ហើយម្យ៉ាងទៀត គណៈកម្មាធិការ នៅក្នុងសន្និបាតចុងក្រោយរបស់ខ្លួន បានចាប់ផ្តើមពិនិត្យខ្លឹមសារនៃសេចក្តីរាយការណ៍ស្តីពីសិទ្ធិសំរាប់មនុស្សចាស់ ហើយបញ្ហាដែលបាន ចោទសួរ អាចឱ្យគេបានទទួលនូវសេចក្តីពិស្តារមានប្រយោជន៍ជាច្រើន ។ គណៈកម្មាធិការបានកត់សំគាល់ឃើញ ថារដ្ឋភាគីមួយភាគធំបានអនុវត្តតិចតួចណាស់បើតាមរបាយការណ៍ពីបញ្ហាសំខាន់នេះ ។ ហេតុដូចនេះគណៈកម្មាធិការបានទទួលឱ្យរដ្ឋភាគីទាំងអស់សរសេរដាក់ក្នុងរបាយការណ៍ឱ្យបានច្បាស់លាស់ដើម្បីធ្វើឱ្យស្ថានភាព មនុស្ស ចាស់ទាក់ទងទៅនឹងសិទ្ធិនិមួយៗដែលបានប្រកាសនៅក្នុងសន្ធិសញ្ញាត្រូវបានអនុវត្ត ។ គណៈកម្មាធិការបានអធិប្បាយក្នុងការតាមដានសេចក្តីសង្កេតទូទៅបច្ចុប្បន្ន ពីបញ្ហាពិតប្រាកដដែលចោទលើបញ្ហានេះ ។

## IV. ភាតព្វកិច្ចទូទៅនៃរដ្ឋភាគី

16. ក្រុមប្រជាជនដែលមានមនុស្សចាស់ក៏មានការខុសគ្នាហើយប្លែកៗដែរ ដែលប្រជាជនឯទៀត និងលក្ខណៈរស់ នៅរបស់គេពឹងពាក់ទៅលើស្ថានភាពសេដ្ឋកិច្ច និង វប្បធម៌នៃប្រទេសនោះ មានកត្តាប្រជាសាស្ត្រ បរិដ្ឋាន និង វប្បធម៌ ស្ថានភាពការងារ កេរ្តិ៍បុគ្គល ស្ថានភាពគ្រួសារ កេរ្តិ៍អប់រំ បរិដ្ឋាននៅទីក្រុងនិង ជនបទ វិជ្ជាជីវៈរបស់ កម្មករ និង អ្នកចូលនិវត្តន៍ ។

17. នៅពេលដែលមានមនុស្សចាស់ជរាដែលទទួលបាននូវសុខភាពល្អ និង ស្ថានភាពថវិការអាចទទួលបាននេះ មនុស្សជរាជាច្រើនទៀត ទោះបីក្នុងប្រទេសលូតលាស់ក៏ដោយ ក៏មិនបានទទួលនូវធនធានគ្រប់គ្រាន់ក៏មានក្រុមមនុស្សដែលក្រីក្របំផុតខ្លះនៅឆ្ងាយដាច់ស្រយ៉ាលហើយគ្មានការការពារដែរ ។ នៅក្នុងសម័យមិនជឿនលឿន និង អន់ថយខាងសេដ្ឋកិច្ច មនុស្សចាស់ជរាត្រូវបានគំរាមគំហែង ។ ដូចដែលគណៈកម្មាធិការបានបញ្ជាក់ពីខាងដើម (សេចក្តីសង្កេតទូទៅលេខ 3 ឆ្នាំ 1990 វក្យខ័ណ្ឌ 12) រដ្ឋភាគិទាំងអស់ ទោះបីក្នុងពេលជួបនូវការខ្វះខាតខាងធនធានយ៉ាងណាក៏ដោយ ។

18. វិធីធានាដែលរដ្ឋភាគីត្រូវប្រើដើម្បីដោះស្រាយកតព្វកិច្ចដែលគេបានសន្យាជាមួយនឹង សន្ធិសញ្ញាទាក់ទងមនុស្ស ចាស់ជាគោលការណ៍គឺដូចជាវិធីនានាដែលត្រៀមដើម្បីធានាការប្រតិបត្តិកតព្វកិច្ចផ្សេងទៀត ( សូមអានសេចក្តី សង្កេតទុទៅលេខ 1 1989 ) ។ វិធីទាំងនោះត្រូវកំណត់ពីប្រភេទ និង សារៈសំខាន់ នៃបញ្ហាដែលមានក្នុងរដ្ឋ ដោយមានការត្រួតពិនិត្យជាប្រចាំ អនុម័តនយោបាយ និង កម្មវិធីច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការឆ្លើយតបសេចក្តីត្រូវការអនុម័តច្បាប់ថ្មីក្នុងករណីត្រូវការហើយលុបចោលច្បាប់ស្តែងចេញពីការរើសអើង ហើយជាទី បញ្ចប់ចាប់យកវិធានការទាក់ទងថវិកា ឬ ក្នុងការជាពិសេសជំរុញឱ្យកិច្ចសហប្រតិបត្តិការអន្តរជាតិ ដូចដែលបានត្រៀមនៅក្នុង មាត្រា 22 និង 23 នៃសន្ធិសញ្ញា អាចផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍន៍នូវមធ្យោបាយសំខាន់ៗ ក្នុងការបំពេញកតព្វកិច្ចរបស់សន្ធិសញ្ញា ។

19. ទាក់ទងបញ្ហានេះ ត្រូវយកចិត្តទុកដាក់លើទិសដៅពិភពលោកលេខ 1 យល់ព្រមដោយមហាសន្និបាតនៅឆ្នាំ 1992 ក្នុងនោះ គេបានស្នើឱ្យបង្កើតរចនាសម្ព័ន្ធជាតិដើម្បីទ្រទ្រង់ ដើម្បីផ្សព្វផ្សាយនយោបាយ និង កម្មវិធីដោយ រាយការណ៍ពីជរាភាពនៅក្នុងផែនការនិង កម្មវិធីជាតិ និង អន្តរជាតិដើម្បីអភិវឌ្ឍន៍ ។ ទាក់ទងបញ្ហានេះដែរ គណៈកម្មាធិការកត់សំគាល់ឃើញថា គោលការណ៍មួយស្តីពីមនុស្សចាស់របស់សហប្រជាជាតិ ដែលបានលើកទឹក ចិត្តដល់រដ្ឋាភិបាលនានាឱ្យដាក់ចូលទៅក្នុងកម្មវិធីរបស់ខ្លួន ដើម្បីឱ្យមនុស្សចាស់អាចបង្កើតជាចលនា ឬ សមាគម មនុស្សចាស់បានផង ។

V. បទបញ្ញត្តិជាត់លាត់នៃសន្ធិសញ្ញា

## មាត្រា 3 : សមភាពរវាងសិទ្ធិបុរសនិងស្ត្រី

20. អនុលោមតាមមាត្រា 3 នៃសន្ធិសញ្ញា ដែលបានបញ្ជាក់ថា រដ្ឋភាគីទាំងអស់សន្យាធានាច្បាប់ស្មើៗគ្នារវាង បុរស និង ស្ត្រីជាប្រយោជន៍ចំពោះសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ ។ គណៈកម្មាធិការពិចារណាឃើញថា រដ្ឋភាគីទាំង ត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា ចំពោះស្ត្រីចាស់ជរាដែលបានតស៊ូជាមួយជីវិត ឬមួយចំណែកនៃជីវិតរបស់គាត់ ដើម្បីគ្រប់គ្រងគ្រួសារដោយមិនគិតពីប្រាក់លើសកម្មភាព របស់កាត់ ទីស្នាក់អាស្រ័យ និង ការចិញ្ចឹមជីវិតពេលចាស់ជរា ឬ មិនបានគិតទាល់តែសោះអំពីសិទ្ធិទទួលនូវទីស្នាក់អាស្រ័យនៅ និង ចិញ្ចឹមជីវិតនៅពេលគាត់មេម៉ាយ ហើយដែលរស់នៅក្នុងស្ថានភាពលំបាកជាទីបំផុត ។

21. ដើម្បីប្រឈមនិង ស្ថានភាពរបៀបនេះ និង ដោះស្រាយបទបញ្ញត្តិក្នុងមាត្រា 9 នៃសន្ធិសញ្ញា និងនៅវាក្យខ័ណ្ឌ 2 h) នៃសេចក្តីថ្លែងការណ៍ស្តីពីជរាភាព រដ្ឋភាគីទាំងអស់ត្រូវបង្កើតផែនការផ្គត់ផ្គង់ជនចាស់ជរាគ្រប់ៗរូបដោយគ្មានការបែងចែកខាងភេទ ដែលគ្មានទ្រព្យសម្បត្តិនឹងគេ ហើយកំណត់អាយុដោយមានចែងនៅក្នុងច្បាប់របស់ជាតិផង ។ ដោយសង្ឃឹមថាការរស់នៅបេស់ស្ត្រីមានកិរិតខ្ពស់ ហើយគឺស្ត្រីនេះហើយដែលជាញឹកញយមិនដែលបានទទួលបាននូវការទំនុកបំរុងខាងលំនៅដ្ឋាន និង ចំណីអាហារដោយមកពីកំហុសនៃអង្គាសប្រាក់ទុកសំរាប់ចូល និវត្តន៍ ហើយគឺស្ត្រីចេះហើយដែលត្រូវតែទទួលបាននូវផលជាទីគាប់ចិត្តនោះ ។

## មាត្រា 6 ដល់ 8 សិទ្ធិទាក់ទងការងារ

22. មាត្រា 6 នៃសន្ធិសញ្ញាៈ រដ្ឋភាគីទាំងអស់ត្រូវបាន ជំរុញការចាត់វិធានការណ៍សមស្របនានា ដើម្បីធានាសិទ្ធិដល់ជនគ្រប់រូបឱ្យបានទទួលនូវលទ្ធភាពចិញ្ចឹមជីវិតរបស់គេដោយការជ្រើសរើស ការងារដោយសេរី និងអាចទទួលយ៉ាងពេញចិត្ត ។ អាស្រ័យហេតុនេះហើយបានជាគណៈកម្មាធិការមើលឃើញថាកម្មករចាស់ៗពុំឈានដល់អាយុ ចូលនិវត្តន៍បានជួបប្រទះនូវវិបត្តិស្វែងរកការងារ ឬ រក្សា

ទុកការងារដែលជាហេតុធ្វើឱ្យគណៈកម្មាធិការទទួលឱ្យ អនុម័តយកវិធានការណ៍ច្បាស់លាស់ ដើម្បីជៀសវាងការរើសអើង ខាងអាយុក្នុងវិស័យរកការងារធ្វើ និង វិជ្ជាជីវៈ ។

23. ច្បាប់ដែលចែងថាមនុស្សគ្រប់រូបត្រូវតែ ទទួលបាននូវលក្ខណៈការងារ យុត្តិធម៌ និង សមរម្យ ។ ដែលប្រកាសនៅក្នុងមាត្រា 7 នៃសន្ធិសញ្ញាបានឆ្លុះបញ្ចាំងឱ្យឃើញជាពិសេសសារៈសំខាន់សំរាប់បរិដ្ឋាន វិជ្ជាជីវៈសំរាប់កម្មករ ចាស់ៗ ដែលត្រូវតែអាចធ្វើការងារ រហូតដល់អាយុចូលនិវត្តន៍ ។ គេក៏ត្រូវចេះវាយតម្លៃចំពោះការពិសោធន៍ និង ចំណេះដឹងរបស់កម្មករទាំងនោះផងដែរ ។

24. កម្មវិធីរៀបចំសំរាប់ចូលនិវត្តន៍ ត្រូវតែចាត់ប្រតិបត្តិការណ៍ឆ្នាំមុន និង បញ្ចប់ជីវិតការងារដោយមានការចូលរួមពីអង្គការតំណាងនិយោជក និង តំណាងកម្មករ និង អង្គភាពទាក់ទិនដទៃទៀតដើម្បីរៀបចំកម្មករចាស់ៗឱ្យគាត់បែរទៅរករបៀបរស់នៅថ្មីរបស់គាត់ ។ កម្មវិធីឯណាក្តីត្រូវតែផ្តល់ពត៌មានស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ជន ចូលនិវត្តន៍ លទ្ធភាពនិង លក្ខណៈផ្សេងៗក្នុងការតាមដានសកម្មភាពវិជ្ជាជីវៈ ក៏ដូចជាលទ្ធភាពក្នុងការធ្វើអំពើល្អ មធ្យោបាយក្នុងប្រឆាំងទល់នឹង ហេតុផលឧបទ្រពចង្រៃនៃជរាភាព បង្ករភាពងាយស្រួលឱ្យពួកគាត់បានចូលរួម ក្នុងសកម្មភាពអប់រំ និង វប្បធម៌ និង ប្រើប្រាស់ភាពទំនេរឱ្យបានរីករាយ ។

25. សិទ្ធិការពារក្នុងមានត្រា 8 នៃសន្ធិសញ្ញា គឺសិទ្ធិខាងបង្កើតសហជីព គឺកម្មករចាស់ៗអាចរៀបចំធ្វើបាន ហើយអាច ធ្វើបានទោះបីបន្ទាប់ពីអាយុចូលនិវត្តន៍ក៏ដោយ ។

### មាត្រា 9 : សិទ្ធិសន្តិសុខសង្គម

26. មាត្រានៃសន្ធិសញ្ញាបានចែងទូលំទូលាយថា រដ្ឋភាគីទាំងអស់ " ទទួលស្គាល់សិទ្ធិសន្តិសុខសង្គមសំរាប់មនុស្សទាំង អស់ " ដោយមិនបញ្ជាក់ពីប្រភេទ និង កំរិតការពារដែលត្រូវធានានោះយ៉ាងណានោះ

ទេ ។ ក៏ប៉ុន្តែពាក្យ "សន្តិសុខសង្គម" វាគ្របដណ្តប់ទៅលើគ្រោះថ្នាក់ទាំងអស់ទាក់ទងការបាត់បង់មធ្យោបាយ ទ្រទ្រង់ជីវភាពដោយ ខ្វះឱកាសឯករាជ្យខាងឆន្ទៈនៃមនុស្សពាក់ព័ន្ធ ។

27. អនុលោមទៅតាមមាត្រា 9 នៃសន្ធិសញ្ញា និង បទបញ្ញត្តិអនុវត្តអនុសញ្ញា OIT ស្តីពីសន្តិសុខសង្គម អនុ សញ្ញាលេខ 102 (1952) ទាក់ទងសន្តិសុខសង្គម (បទដ្ឋានអប្បបរិមា) និងអនុសញ្ញាលេខ 128 (1967) ទាក់ទងការទំនុកបំរុងដល់ជនពិការភាពជនជរា និងអ្នកផុតពីសេចក្តីស្លាប់ រដ្ឋភាគីទាំងអស់ត្រូវតែចាត់វិធានការណ៍ សមស្របដើម្បីជួយទំនុកបំរុងដល់ជនចាស់ជរា ជាចាំបាច់ ដែលត្រូវអនុវត្តចាប់ពីអាយុកំណត់ហើយសរសេរចូល ទៅក្នុងច្បាប់របស់ជាតិ ។

28. ដោយអនុលោមទៅតាមអនុសាសន៍បានចែងនៅក្នុងអនុសញ្ញា OIT ខាងលើ និង ក្នុងលិខិតអនុសាសន៍លេខ 162 គណៈកម្មាធិការអញ្ជើញរដ្ឋភាគិទាំងអស់ឱ្យមកកំណត់អាយុចូលនិវត្តន៍ឱ្យបានត្រូវតាមសកម្មភាព ដែលធ្វើ និង សមត្ថភាពការងាររបស់មនុស្សចាស់ ហើយក៏ត្រូវគិតគូរដល់កត្តាប្រជាសាស្ត្រសេដ្ឋកិច្ច និង សង្គមផងដែរ ។

29. ដើម្បីដាក់ឱ្យអនុវត្តន៍បទបញ្ញត្តិក្នុងមាត្រា 9 នៃសន្ធិសញ្ញារដ្ឋភាគិទាំងអស់ត្រូវតែធានាផ្គត់ផ្គង់ដល់ជនរួចពីស្លាប់ និង ក្មេងកំព្រាឪពុកម្តាយ ដែលត្រូវក្នុងកោលការណ៍សន្តិសុខសង្គម ឬ អ្នកទទួលផលប្រយោជន៍ពីប្រាក់ចូល និវត្តន៍ ។

30. ទីបញ្ចប់ ដើម្បីដាក់ឱ្យអនុវត្តនូវបទបញ្ញត្តិមាត្រា 9 នៃសន្ធិសញ្ញាឱ្យបានពេញលេញ ហើយដូចដែលគណៈកម្មាធិការបានបញ្ជាក់នូវវាក្យខ័ណ្ឌ 20 និង 21 រួចហើយរដ្ឋភាគិទាំងអស់ត្រូវតែបង្កើតក្នុងក៏វិតធនធានដែលមាននូវ កម្មវិធីទំនុកបំរុងជនចាស់ជរាដោយមិនយកកំរៃ ឬ ការជួយផ្សេងៗទៀតចំពោះមនុស្សចាស់ជរាដែលដល់អាយុ ចែងនៅក្នុងច្បាប់ជាតិ តែគាត់ពុំមានការងារធ្វើ ឬ ក៏បានដាក់ប្រាក់រៃអង្គាសក្នុងរយៈពេលអប្បបរិមាដែលតម្រូវឱ្យ នឹងពុំមានសិទ្ធិដាក់ប្រាក់ចិញ្ចឹមខ្លួន សំរាប់ចាស់

ឬ ការផ្គត់ផ្គង់ផ្សេងទៀត ក្នុងនាមសន្តិសុខសង្គម ហើយ ក៏មិនទទួលប្រយោជន៍ ពីប្រភពចំណូលឡើយ ។

## មាត្រា 10 : ការការពារគ្រួសារ

31. ដោយអនុលោមតាមវាក្យខ័ណ្ឌ 1 មាត្រា 10 នៃសន្ធិសញ្ញា និង អនុសាសន៍លេខ 25 និង 29 នៃផែនការណ៍ ការងារអន្តរជាតិ ទីក្រុង Vienne ស្តីពីមនុស្សចាស់ រដ្ឋភាគីទាំងអស់ត្រូវតែប្រឹងប្រែងគ្រប់មធ្យោបាយចាំបាច់ ដើម្បីទ្រទ្រង់ ការពារនិងពង្រឹងគ្រួសារ និង ជួយគ្រួសារអនុលោមតាមតម្លៃវប្បធម៌នៃសង្គមនិមួយៗ ផ្គត់ផ្គង់ សេចក្តីត្រូវការនៃសមាជិកចាស់ៗ ក្រោមបន្ទុក ។ នៅក្នុងអនុសាសន៍ លេខ 29 រដ្ឋាភិបាល និង អង្គការក្រៅ រដ្ឋាភិបាលទាំងអស់បានសន្យាចាត់ វិធានការជួយសង្គម ជាប្រយោជន៍ដល់គ្រួសារទាំងឡាយដែលបីបាច់ថែរក្សាជនចាស់ជរា និងចាត់វិធានការណ៍ជាពិសេសជួយគ្រួសារ ដែលរកចំណូលបានទាប ហើយចង់ចិញ្ចឹមបីបាច់ថែរក្សាមនុស្សចាស់ ។ ជនទាំងឡាយដែលចង់រស់នៅតែឯង ឬក៏ប្តីប្រពន្ធចាស់ៗដែលចង់រស់នៅផ្ទះរបស់ខ្លួនក៏ត្រូវបានទទួលគុណប្រយោជន៍ ពីជំនួយនេះដែរ ។

## មាត្រា 11: សិទ្ធិទទួលកម្រិតជីវភាពគ្រប់គ្រាន់

32. គោលការណ៍ 1 របស់សហប្រជាជាតិ ដើម្បីមនុស្សចាស់ ទាក់ទង និង ឯករាជ្យភាពរបស់មនុស្សចាស់បានចែង មុនទេ " មនុស្សចាស់ត្រូវតែទទួលបាននូវស្បៀងអាហារ ទឹក លំនៅដ្ឋាន សំលៀកបំពាក់និងការថែទាំសុខភាពតាមរយៈចំណូលរបស់គាត់ ការទ្រទ្រង់របស់គ្រួសារ និង សហគមន៍ និងការជួយគ្នាទៅវិញទៅមក" ។ គណៈកម្មាធិការ បានវិនិច្ឆ័យទៅឃើញថា គោលការណ៍នេះដែលទទួលស្គាល់សិទ្ធិមនុស្សចាស់ជរាដូចបានប្រកាសក្នុងមាត្រា 11 នៃសន្ធិសញ្ញានេះមានសារៈសំខាន់ណាស់ ។

33. ទៅក្នុងអនុសាសន៍ពីលេខ 19 ដល់ 24 នៃផែនការណ៍ការងារអន្តរជាតិនៅទីក្រុង Vienne ស្តីពីជរាភាពបាននិយាយថា លំនៅដ្ឋានសំរាប់មនុស្សចាស់មិនត្រូវធ្វើឱ្យសញ្ញាដូចជាជំរកពេកទេ តែ

លក្ខណៈ និងសភាពខាង ក្រៅវាផ្សារភ្ជាប់ និង ចិត្តសាស្ត្រ និងសង្គម ដូច្នេះយើងត្រូវតែយកចិត្តដាក់ពីបញ្ហានេះផង់ ។ ហេតុអ្វីបានជា នយោបាយរបស់ជាតិត្រូវជួយមនុស្សចាស់ដើម្បីឱ្យគាត់បន្តរស់នៅនៅផ្ទះរបស់ឱ្យបានយូរដែលអាចធ្វើទៅបាន ដើម្បីឱ្យពួកគាត់អាចរៀបចំចាត់ចែងឡើងវិញ នឹងកែលំអលំនៅដ្ឋាន និង សំរបសំរួលខ្លួនគាត់ ដើម្បីទទួលនូវសិទ្ធិ ផ្សេងៗជាមនុស្សចាស់ ( អនុសាសន៏លេខ 19 ) ។ អនុសាសន៏លេខ 20 សង្កត់លើការចាំបាច់ក្នុងការឃ្លាំមើលបទ បញ្ជារ និងផែនការភារូបនីយកម្មអភិវឌ្ឍន៏និងការរៀបចំជាថ្មីឡើងវិញនូវកន្លែងក្នុងក្រុងឱ្យទៅជាកន្លែងពិសេស មួយសំរាប់ជនចាស់ជរាដើម្បីសំរួលដល់គាត់ឱ្យអាចរស់នៅបានស្រួល ។ ហើយអនុសាសន៏ទី 22 ក៏បានយកចិត្ត ទុកដាក់លើសមត្ថភាពមុខងាររបស់មនុស្សចាស់ ដើម្បីផ្តល់ដល់គាត់នូវបរិដ្ឋានជួយឱ្យគាត់មានការធ្វើចលនាកំរើក និងបង្ករលក្ខណៈឱ្យគាត់បានជួបគ្នា ដោយត្រៀមរៀបចំមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ជូនគាត់ ។

## មាត្រា 12 សិទ្ធិសុខភាពផ្លូវកាយ និងចិត្ត

34. ដើម្បីឃ្លាំមើលថាតើមនុស្សចាស់បានទទួលនូវសិទ្ធិខាងសុខភាព ផ្លូវកាយ និងចិត្តដល់កំរិតដែលចង់បាន ដោយអនុសលោមតាមបទបញ្ញាតិនៅវក្យខ័ណ្ឌ 1 មាត្រា 12 នៃសន្ធិសញ្ញារដ្ឋភាគីទាំងអស់ត្រូវតែអនុវត្តតាម អនុសាសន៏ពីលេខ 1 ដល់លេខ 17 នៃផែនការការងារអន្តរជាតិនៅទីក្រុង Vienne ស្តីពីជរាភាព ដែលសំដៅលើ ការផ្តល់ទិសស្តីពីនយោបាយសុខាភិបាល សំរាប់មនុស្សចាស់ និង សំដៅលើទិដ្ឋភាពរួមមានការការពារ និងជួយថែទាំជួយដល់អ្នកជម្ងឺនៅពេលបញ្ចប់នៃជីវិតរបស់ គាត់ ។

35. ជាការពិតណាស់ដែលយើងមិនអាចប្រឈម និងករណីជម្ងឺរាំរៃ និងធ្ងន់ធ្ងរជាច្រើន និងតម្លៃសំរាកពេទ្យដ៏ខ្ពស់ដោយមកពីថ្នាំចាក់ព្យាបាលនោះ ។ រដ្ឋភាគីទាំងអស់ត្រូវតែគិតឱ្យបានល្អិតល្អន់ថា ការគាំពារឱ្យមានស្ថានភាពសុខភាពល្អ នៅពេលគាត់ជរាតម្រូវឱ្យមានការធ្វើវិនិយោគលើជីវភាពពលរដ្ឋរហូតពីក្មេងដល់ចាស់ ជាពិសេស ដោយសារការអនុម័តយករបៀបរស់នៅប្រកប ដោយសុខភាព ល្អ (ម្ហូបអាហារការគាត់ និង ការឈប់ពិសារបារី និងស្រា ។ល។ ) ។ ការការពារតាមរបៀបត្រួត

ពិនិត្យជាប្រចាំ នូវសេចក្តីត្រូវការរបស់បុរស និងស្ត្រីចាស់ជរា ដើរតួនាទីសំខាន់បំផុត ក៏ដូចជាការធ្វើការងារ ឬហាត់ប្រាណដែរ ធ្វើឱ្យគាត់ទ្រទ្រង់បាននូវមុខងារមួយរបស់សំខាន់មនុស្សចាស់ ហើយអាចកាត់បន្ថយនូវឈ្នួលថៃទាំខាងពេទ្យ និង សេវាសង្គម ។

## មាត្រា 13 ដល់ 15 : សិទ្ធិអប់រំនិងវប្បធម៌

36. វាក្យខ័ណ្ឌ 1 មាត្រា 13 នៃសន្ធិសញ្ញាទទួលស្គាល់សិទ្ធិអប់រំសំរាប់ មនុស្សគ្រប់រូប ។ ក្នុងករណីមនុស្សចាស់ សិទ្ធិនេះត្រូវគិតគូរបែងចែកជាមុខ 2 ផ្សេងគ្នា និងបន្ទាបបន្សំ:

ក/ សិទ្ធិមនុស្សចាស់ ដែលអាចទទួលបាននូវកម្មវិធី អប់រំ និង

ខ/ ការទាញយកចំណេះដឹង និង បទពិសោធន៍ពីមនុស្សចាស់សំរាប់យុវជនជំនាន់ក្រោយ ។

37. រដ្ឋភាគីទាំងអស់ត្រូវតែយកចិត្តទុក ក/ពីអនុសាសន៍ដែលដាក់តែងនៅក្នុងគោលការណ៍ 16 របស់សហប្រជាជាតិ សំរាប់មនុស្សចាស់ គឺថាមនុស្សចាស់ត្រូវតែទទួលបាននូវកម្មវិធីសិក្សាសមរម្យ និងការបណ្តុះបណ្តាល ។ ហើយតាមក៏រិតនៃការរៀបចំរបស់គាត់ សម្បទាន និង យុត្តិកម្មរបស់គាត់ ទទួលនូវដំណាក់កាលអប់រំខុសៗគ្នា តាមវិធានការពិសេសតាមលេខរៀងអក្សរ ការអប់រំអចិន្ត្រៃយ៍ ការសិក្សាសកលវិទ្យាល័យ ។ល។ និង ខ/ពីអនុសាសន៍លេខ 47 នៃផែនការការងារអន្តរជាតិទីក្រុង Vienne ស្តីពីមនុស្សចាស់ យោងតាមអត្ថន័យ នៃការអប់រំអចិន្ត្រៃយ៍ដែលអនុញ្ញាតិឱ្យប្រើដោយអង្គការ UNESCO គេត្រូវមានកម្មវិធីក្រៅផ្លូវការជាច្រើន ផ្អែកលើសមូហភាព និង តំរង់ទិសទៅរកភាពរីករាយសំរាប់មនុស្សចាស់ ដើម្បីផ្តល់ដល់គាត់នូវមនោសញ្ចេតនា ស្វ័យត និង ទទួលខុសត្រូវ បែបសមាគមន៍ ។ រដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល ត្រូវតែគាំទ្រកម្មវិធីអស់ទាំងនេះ ។

38. ចំពោះបញ្ហាដែលត្រូវចាប់យកចំពោះវិជ្ជា និង បទពិសោធន៍ពីមនុស្សចាស់ដែលនិងនៅក្នុងអនុសាសន៍ នៃផែនការការងារអន្តរជាតិនៅទីក្រុង Vienne ស្តីពីជរាភាពទាកទង់ការងារអប់រំ (វាក្យ

ខ័ណ្ឌ 74-76) រដ្ឋភាគីទាំងអស់ ត្រូវតែមានតួនាទីសំខាន់ហើយចាត់ទុកមនុស្សនឹង ព្រឹទ្ធាចារ្យជាអ្នកដែលដើរតួសំខាន់ក្នុងសង្គម ពីព្រោះពួកគាត់ ជាអ្នកទទួលបញ្ជូនពត៌មាន ចំណេះដឹងប្រពៃណី និង តម្លៃស្មារីជាតួនាទី តែមិនអាចសាបសូន្យឡើយ ។ អាស្រ័យហេតុនេះហើយបានជាគណៈកម្មាធិការ យកចិត្តទុកដាក់ជាពិសេសលើសារថែងក្នុងអនុសាសន៍លេខ 44 នៃផែន ការដែលថា " គេត្រូវបង្កើត ឱ្យមានកម្មវិធីសិក្សាដែលធ្វើឱ្យមនុស្សដើរតួនាទីជាគ្រូបង្រៀន និង ជាចរន្តបន្តខាង ផ្នែកចំណេះដឹង វប្បធម៌ និង តម្លៃស្មារតី" ។

39. អនុលោមតាមវគ្គ a) និង b) នៃវក្យខ័ណ្ឌ 1 មាត្រា 15 នៃសន្ធិសញ្ញា រដ្ឋភាគីទាំងអស់ទទួលស្គាល់ សិទ្ធិមនុស្សម្នាក់ៗក្នុងការចូលរួមជីវភាពវប្បធម៌ និង ការអនុវត្ត ។ ចំពោះរឿងនេះ គណៈកម្មាធិការ កំណត់ឱ្យរដ្ឋភាគីទាំង អស់ទទួលយកនូវអនុសាសន៍ដែលមាននៅក្នុងគោលការណ៍ 7 ចែងថា " មនុស្សចាស់ត្រូវតែរស់នៅក្នុងសង្គម ចូលរួមយ៉ាងសកម្មក្នុងការតាក់តែង និង អនុវត្តនយោបាយ នានា ពាក់ពន្ធ័ទៅនឹងសុខមាលភាពហើយចែកចាយ ចំណេះវិជ្ជានិង ការប៉ិនប្រសប់ដល់យុវវ័យជំនាន់ក្រោយ" ។ ឯចំណែកគោលការណ៍ 16 ចែងថា" មនុស្សចាស់ត្រូវ តែទទួលបាននូវធនធានផ្សេងៗពី សង្គមលើផែនការណ៍ អប់រំ វប្បធម៌ ស្មារតី និង ស្តីពីការលំហែ" ។

40. អនុលោមតាមអនុសាសន៍លេខ 48 នៃផែនការណ៍ការងារអន្តរជាតិនៅទីក្រុង Vienne ស្តីពីជរាភាព រដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលទាំងអស់ត្រូវសន្យាគាំទ្រកម្មវិធី ដែលសំដៅលើការ សំរួលផ្នែករូបកាយមនុស្សចាស់ ឱ្យជួយឋមនភ័ណ្ឌវប្បធម៌ (សារមន្ទីរ ល្ខោន សាលប្រគុំតន្ត្រី រោង ភាពយន្ត ។ល។

41. អនុសាសន៍លេខ 50 បានសង្កត់លើការចាំបាច់របស់រដ្ឋាភិបាលអង្គការក្រៅរដ្ឋាភិបាល និង មនុស្សចាស់ក្នុងការប្រឹងប្រែងលុបបំបាត់ផ្ទាំងពុម្ព របស់មនុស្សចាស់ដែលអសមត្ថភាពខាងផ្លូវកាយ និង ចិត្តសាស្ត្រ អសមត្ថភាព ក្នុងការបំពេញមុខងារស្ម័គ និង គ្មានតួនាទី គ្មានទីកន្លែងនៅក្នុងសង្គម ។

ការប្រឹងប្រែងទាំងនេះ ដោយត្រូវមាន ការចូលរួមពីមធ្យោបាយគមនាគមន៍ និង ការសិក្សាមានសារៈសំខាន់ណាស់ ក្នុងការកសាងសង្គមមួយដែលអាច ការពារមូរណភាពគ្រប់គ្រាន់របស់មនុស្សចាស់ ។

42. ជាទីបញ្ចប់ទាក់ទងនឹង សិទ្ធិទទួល ភាពលូតលាស់ខាងវិទ្យាសាស្ត្រ និង ការអនុវត្តរដ្ឋភាគីទាំងអស់ត្រូវយកចិត្ត ទុកដាក់លើអនុសាសន៍លេខ 60-61 និង 62 នៃផែនការណ៍ការងារអន្តរជាតិនៅទីក្រុង Vienne និង បង្កើនការប្រឹងប្រែងដើម្បីលើកទឹកចិត្តដល់ការស្រាវជ្រាវក្នុងវិស័យរូបសាស្ត្រ ចិត្តសាស្ត្រនិងសង្គម និង លើមធ្យោបាយ ជួយទ្រទ្រង់សមត្ថភាពផ្នែកមុខងារ និង ជៀសវាងចំពោះបញ្ហានេះ គេត្រូវស្នើដល់រដ្ឋនិងអង្គការក្រៅរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល បង្កើតឡើងនូវអាគារពិសេសសំរាប់សិក្សាផ្នែកការគ្រប់គ្រងដោយមនុស្សចាស់ នៅក្នុងប្រទេសដែលពុំដែលមានអាគារបែបនេះទាល់តែសោះ ។

### កំណត់សំគាល់

- បង្ហាញនៅក្នុងឯកសារ E/1996/22

1. ទិសដៅពិភពលោកទាក់ទងជរាភាពសំរាប់ ឆ្នាំ 2001 យុទ្ធសាស្ត្រជាក់ស្តែង របាយការណ៍របស់អគ្គលេខា ធិការ ( A/47 /339 វាក្យខ័ណ្ឌ 5 )
2. របាយការណ៍នៃមហាសន្និបាតពិភពលោកស្តីពីជរាភាពទីក្រុង Vinne ថ្ងៃទី 26 កក្កដា ទី 6 សីហាឆ្នាំ 1982 ( ការចេញផ្សាយរបស់សហប្រជាជាតិ លេខ F.82.1.16 ) ។
3. សេចក្តីសំរេច 46/91 នៃមហាសន្និបាតអង្គការសហប្រជាជាតិថ្ងៃទី 16 ធ្នូ 1991 ទាក់ទងការអនុវត្តផែន ការណ៍ការងារអន្តរជាតិស្តីពីជរាភាព និង សកម្មភាពប្រទាក់គ្នា - ឧបសម្ព័ន្ធ។
4. ទិសដៅពិភពលោកទាក់ទងជរាភាពសំរាប់ឆ្នាំ 2001 យុទ្ធសាស្ត្រជាក់ស្តែង (A/47/339 ជំពូក III និង IV ។
5. សេចក្តីសំរេច 47/5 នៃមហាសន្និបាត ថ្ងៃទី 16 តុលា 1992 " សេចក្តីប្រកាសស្តីពីជរាភាព " ។

6. សូមអានអនុសាសន៍លេខ 162 , 1980 របស់ OIT ទាក់ទងកម្មករចាស់ៗ ( វាក្យខ័ណ្ឌ 3 ដល់ 10 )
7. Ibid ( វាក្យខ័ណ្ឌ 11 ដល់ 19 )
8. Ibid ( វាក្យខ័ណ្ឌ 30 )

## បណ្ណាល័យសាស្ត្រទូទៅ


- Albouy, Francois – Xavier Y Kessler, Denis. ប្រព័ន្ធស្តីពីការចូលនិវត្តន៍នៅទ្វីបអឺរ៉ុប : គំនិតហួសហេតុមួយតើបានសំរេចដែរឬ ទេ ? ទស្សនាវដ្តីបារាំងស្តី ពីកិច្ចការសង្គម ខែ វិច្ឆិកា ឆ្នាំ 1989 ។
- Aranguren, José Luis, La vejèz como ការសំរេចស្វ័យប្រវត្តិដោយខ្លួនឯង និង ដោយសង្គម ។ ក្រសួងកិច្ចការសង្គមម៉ាឌ្រីត 1992 ។
- Beauvoir, Simore ស្តីពីភាពចាស់ជរា Fallimard 1970 ( Edhasa, 1983)
- Cebrian Badia, Francisco Javier : La jubilacion forzosa del trabajador y suderecho al trabajo Actualidad Laboral No 14, Madrid 1991
- គណកម្មការសហគមន៍អឺរ៉ុបៈ អឺរ៉ុបក្នុងចលនាស្តីពីប្រជាជន ( អណត្តិថ្ងៃ 21 មិថុនា 1989 ) ទីក្រុង Brusseles មិថុនា 1990 ។
- Duran Herao, Alinudena. Antiapo de la jubilacion en Espana. Revista de Seguridad Social, N. 41, Madrid 1989.
- Fuenteo, C. Josefa. Situacion Social del Anciano Alcalà de Henareo, 1975
- Fundacion Europea Para la Mejora de las condiaciones de Vida y de Trabajo. Informe Annual 1989 Luxembourg. Oficina de las pubblicaciones oficiales de las comunidades Europeas, 1990 ។
- Girard, Paulelte. ជរាភាពនិង មុខរបរជរាភាព និង ការងារ ។ ក្រុមប្រឹក្សាជាន់ខ្ពស់ប្រជាជន និង គ្រួសារ ឯកសាររបស់បារាំង 1989 ។
- Guillemard, Anne Marie. Aralisis de las Politics de vejez en Europa. ក្រសួងកិច្ចការសង្គម ម៉ាឌ្រីត 1992 ។

- Guillemard, Anne Marie. ការបំពេញការងារ ការការពារសង្គម និង វដ្តនៃជីវិត : លទ្ធផលនៃការ ប្រៀបធៀបអន្តរជាតិ ស្ដីពីការការពារត្រៀមជាមុន ចំពោះសកម្មភាព ។ សង្គមវិទ្យា ការងារ លេខ ៣ Paris 1993 ។